គម្រោងបន្លែសុវត្ថិភាព “នវានុវត្តសម្រាប់បង្កើត និងពង្រីកខ្សែសង្វាក់តម្លៃបន្លែសុវត្ថិភាពក្នុងប្រទេសកម្ពុជា”

Project Safe Vegetable “Innovation to Build and Scale Safe Vegetable Value Chain in Cambodia”

ការជ្រើសរើសដាំបន្លែសុវត្ថិភាព នៅក្នុងផ្ទះសំណាញ់ជាបច្ចេកវិទ្យាមួយដ៏សាមញ្ញដែលវាមានប្រយោជន៍ក្នុងការពារបន្លែពីពពួកសមាសភាពចង្រៃផ្សេងៗ។ មួយវិញទៀតការដាំបន្លែសុវត្ថិភាពជាវិធីសាស្ត្រក្នុងការលើកកម្ពស់សុខមាលភាពប្រជាពលរដ្ឋតាមរយៈការមិនប្រើប្រាស់ថ្នាំ និងជីគីមីកសិកម្មដែលវាជាបញ្ហាដ៏ធំក្នុងការជះឥទ្ធិពលដល់សុវត្ថិភាពអ្នកប្រើប្រាស់ និងអ្នកបរិភោគ។ ការដាំបន្លែសុវត្ថិភាពក្នុងផ្ទះសំណាញ់អាចជួយលើកកម្ពស់ជីវភាពកសិករ សុខភាព បរិស្ថាន និងកាត់បន្ថយការចំនាយលើថ្នាំ និងជីកសិកម្មបានមួយចំនួនធំ។ ក្នុងនោះដែល គម្រោងផ្ទះសំណាញ់ដែលបាន និងកំពង់សាងសង់រួចនៅក្នុងស្រុកថ្មគោលបានចំនួន ៨ ផ្ទះសំណាញ់ ដែលវាស្ថិតនៅក្នុង ភូមិ ចំនួន ៣ គឺ ភូមិអន្លង់រុន ភូមិគ្រួស និងភូមិតាសុី នៃស្រុកថ្មគោល ខេត្តបាត់ដំបង។ ជាមួយនេះដែលជាសមទ្ធផលឃើញថាកសិករពិតជាទទួលបានប្រាក់កម្រៃខ្ពស់ និងឥត្ថប្រយោជន៍បន្ថែមជាច្រើនដែលទទួលបានពីការដាំបន្លែក្នុងផ្ទះសំណាញ់។

## កិច្ចប្រជុំជាមួយកសិករក្នុងការបជ្រាបការយល់ដឹងទាក់ទង និងការដាំបន្លែសុវត្ថិភាពដោយប្រើប្រាស់ផ្ទះសំណាញ់






## សកម្មភាពមន្ត្រីគម្រោងចុះអនុវត្តការសាងសង់ផ្ទះសំណាញ់នៅក្នុងភូមិ តាសី ឃុំតាម៉ឺន ស្រុកថ្មគោល ខេត្តបាត់ដំបង







វីធីសាស្រ្តក្នុងការតំទ្បើងផ្ទះសំណាញ់
- រៀបចំដី
- ស្វែងរកគ្រោងឆ្អឹង (ឬស្សី ឈើ ឬបំពង់ដែក)
- រៀបចំតំទ្បើងគ្រោងឆ្អឹងផ្ទះសំណាញ់ (ឆ្អឹងកណ្តាលមានកម្ពស់ ៣ម៉ែត្រ ឆ្អឹងសងខាង មានកម្ពស់ ២.៥ ម៉ែត្រ)
- ធ្វើការរៀបចំដេរសំណាញ់ដើម្បីធ្វើការគ្របទៅលើគ្រោងឆ្អឹងដែលបានសាងសង់
- រៀបចំតំទ្បើងទ្វា ដោយទ្វាធ្វើការតំទ្បើងពីជាន់ដើម្បីការពារពពួកសមាសភាពចង្រៃកុំឱ្យជ្រាតចូលទៅក្នុងផ្ទះសំណាញ់
- ទ្វាយើងអាចឆ្នៃវាដោយប្រើ រ៉ូត ដើម្បីងាយស្រួលក្នុងការចេញចូល

## អត្ថប្រយោជន៍នៃការដាំបន្លែក្នុងផ្ទះសំណាញ់

អត្ថប្រយោជន៍ដោយផ្ទាល់
- កាត់បន្ថយធាតុចូលកសិកម្ម
- បង្កើនទិន្នផល
- បង្កើនចំណូល
- បង្កើនតម្លៃលើផលិតផលបន្លែតាមរយៈការផ្គត់ផ្គង់បន្លែសុវត្ថិភាព

អត្ថប្រយោជន៍មិនផ្ទាល់
- លើកកម្ពស់សុខភាព
- កាត់បន្ថយផលប៉ះពាល់បរិស្ថានតាមរយៈការកាត់បន្ថយធាតុចូលកសិកម្ម
- លើកកម្ពស់សុវត្ថិភាពអាហារក្នុងប្រទេសកម្ពុជា
- កាត់បន្ថយការនាំចូលបន្លែពីក្រៅប្រទេស
- លើកកម្ពស់ជីវភាពប្រជាជន

## ខ្សែសង្វាក់ផលិតកម្មបន្លែសុវត្ថិភាព




វិភាគសេដ្ឋកិច្ច
- ការចំណាយខ្ពស់ទៅលើធាតុចូលកសិកម្មក្នុងការដាំដុះដោយមិនប្រើប្រាស់ផ្ទះសំណាញ់
- ទិន្នផលនៃបន្លែដែលដាំក្រៅផ្ទះសំណាញ់មានទិន្នផលទាបជាងបន្លែដែលដាំក្នុងផ្ទះសំណាញ់
- គុណភាពបន្លែដែលដាំក្រៅផ្ទះសំណាញ់មានភាពអន់ជាងបន្លែដែលដាំក្នុងផ្ទះសំណាញ់

ខ្សែសង្វាក់តម្លៃ
- បន្លែដាំក្នុងផ្ទះសំណាញ់ដែលមានផ្ទៃដីទំហំ ២៥០ មែត្រការ៉េអាចរកកម្រៃបាន ៥៧៥០០០ រៀល/ខែ
- បន្លែដាំក្រៅផ្ទះសំណាញ់ដែលមានផ្ទៃដីទំហំ ២៥០ មែត្រការ៉េអាចរកកម្រៃបាន ២២៥០០០ រៀល/ខែ
- បន្លែដែលដាំក្នុងផ្ទះសំណាញ់ដែលមានផ្ទៃដីទំហំ ២៥០ មែត្រការ៉េ ចំណាយលើជីធម្មជាតិអស់ ៦៧៥០០រៀល/ខែ
- បន្លែដែលដាំក្រៅផ្ទះសំណាញ់ដែលមានផ្ទៃដីទំហំ ២៥០ មែត្រការ៉េ ចំណាយលើថ្នាំកសិកម្ម និងជីគីមីអស់ ១៣១០០០រៀល/ខែ